# ប្រ ក ា ស

## ស្តីពី

## កាតព្វកិច្ចអនុវត្តតាមខ្លឹមសារនិងការពិត

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## ស ំ រេ ច

**ប្រការ ១ .-**

គណនេយ្យកម្មរបស់ធនាគារត្រូវបង្ហាញពីទស្សនៈពិតនិងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ និងកាតព្វកិច្ចបើកចំហពតិមាន ស្របទៅតាមគោលការណ៍គណនេយ្យ នៃស្តង់ដាគណនេយ្យអន្តរជាតិនិងស្តង់ដាគណនេយ្យកម្ពុជា ។ វិធានទូទៅនេះត្រូវតែបានអនុវត្ត

ជាពិសេសលើពីរចំណុច គឺ : គោលការណ៍នៃខ្លឹមសារមានទម្ងន់លើទំរង់ និងការទទួលស្គាល់កំរៃការប្រាក់លើមូលដ្ឋានបង្គរ ។

**ប្រការ ២ .-**

ពតិមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងប្រតិបត្តិការ ដោយមិនគ្រាន់តែបំពេញឱ្យត្រឹមត្រូវតាមគោលការណ៍នៃទំរង់ ប៉ុណ្ណោះទេ មានន័យថា ការកត់ត្រាគណនេយ្យត្រូវផ្តល់សារសំខាន់លើខ្លឹមសារជាជាងលើទំរង់ ។

**ប្រការ ៣ .-**

ជាទូទៅ ធនាគារមិនត្រូវប្រើប្រាស់គណនេយ្យសំរាប់លាក់បាំងប្រតិបត្តិការខ្លះ ដោយគ្រាន់តែប្រើប្រាស់ទំរង់ឱ្យស្របតាមច្បាប់និងប្រកាសប៉ុណ្ណោះទេ ចំណែកឯខ្លឹមសារនៃប្រតិបត្តិការបែរជាអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់និងប្រកាសទៅវិញ ។

ជាក់ស្តែង ប្រតិបត្តិការដែលប៉ះពាល់ដល់គោលការណ៍ខ្លឹមសារមានទម្ងន់លើទំរង់ត្រូវបានអនុវត្តតាមរូបភាពជាកិច្ចសន្យាជួលឬទិញអចលនទ្រព្យ ដោយទូទាត់មុនរយៈពេលវែង ប៉ុន្តែតាមខ្លឹមសារ មានន័យថា ម្ចាស់ធនាគារបានដកដើមទុនរបស់ខ្លួនចេញទៅវិញ ។

**ប្រការ ៤ .-**

ក្នុងករណីដែលធនាគារជាតិនៃកម្ពុជារកឃើញប្រតិបត្តិការណាមួយដែលបញ្ជិកាគណនេយ្យមិនបានឆ្លុះបញ្ចាំងពីគោលការណ៍ខ្លឹមសារសេដ្ឋកិច្ច ក៏ប៉ុន្តែដោយគ្រាន់តែតំរូវតាមគោលការណ៍ទំរង់ឬកាតព្វកិច្ចនោះ ប្រតិបត្តិការនេះនឹងត្រូវបានតំរូវឱ្យរៀបចំចុះបញ្ជិកាគណនេយ្យឡើងវិញតាមខ្លឹមសារពិត ។

**ប្រការ ៥ .-**

ក្នុងករណី ភាគទុនិកដកដើមទុនដោយផ្អែកលើគោលការណ៍ទំរង់ដើម្បីបង្កើនប្រាក់ចំណេញឬទ្រព្យសកម្ម ឬកាត់បន្ថយការខាតបង់ឬទ្រព្យអកម្ម ចំនួនប្រាក់នៃប្រតិបត្តិការទាំងនោះ នឹងត្រូវបានដកចេញពីដើមទុនផ្ទាល់និងមូលនិធិផ្ទាល់សុទ្ធ ហើយបើចាំបាច់ធនាគារត្រូវតែបង់បំពេញដើមទុនឡើងវិញ ។

**ប្រការ ៦ .-**

ដោយមិនគិតដល់ប្រការ ៥ ធនាគារជាតិនៃកម្ពុជាអាចដាក់ទណ្ឌកម្មតាមមាត្រាទី ៣៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា និង មាត្រាទី ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៧ .-**

គណនេយ្យកម្មចំណាយនិងចំណូលរបស់ធនាគារត្រូវតែអនុវត្តស្របតាមស្តង់ដាគណនេយ្យកម្ពុជាដែលដូចគ្នាទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិ ។

គណនេយ្យកម្មការប្រាក់ត្រូវបានកំណត់ដូចតទៅ :

- ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលផលប្រយោជន៍សេដ្ឋកិច្ចទៅអនាគតរំពឹងថា អាចហូរចូលទៅក្នុងសហគ្រាស ហើយការរំពឹងទុកពីផលប្រយោជន៍ទាំងនេះត្រូវបានវាស់ស្ទង់ថា អាចជឿទុកចិត្តបាន ។
- ការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានសមាមាត្រពេលវេលាដែលត្រូវយកមកគិតគូរពីប្រសិទ្ធភាពនៃផលចំណូលពីទ្រព្យសកម្ម ។
- ការទទួលស្គាល់ចំណូលនិងចំណាយការប្រាក់មានសារសំខាន់ក្នុងការកំណត់លទ្ធភាពចំណេញរបស់ធនាគារ ។
- ចំណូលការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានបង្គរ លើកលែងតែក្នុងករណីឥណទានមិនដំណើរការនិងឥណទានមិនបានរៀបចំឡើងវិញ ។

**ប្រការ ៨ .-**

ដើម្បីផ្តល់នូវពតិមានប្រកបដោយគុណភាពក៏រិតខ្ពស់ ធនាគារត្រូវកត់ត្រាជាប្រចាំថ្ងៃ នូវៈ

- ការប្រាក់ដែលបានសងនិងបានទទួលពី អតិថិជន ធនាគារ អ្នកជំពាក់បំណុល និងឥណទាយកដ៏ទៃទៀត ។
- ការរំលស់អចលនទ្រព្យនិងទ្រព្យសកម្មផ្សេងៗទៀត ប្រសិនបើចាំបាច់ ។

**ប្រការ ៩ ._**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០ ._**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមិនា ឆ្នាំ២០០៤

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"